មាតុភូមិនិវត្តន៍ ?

ការសម្រេចចិត្ត ធ្វើមាតុភូមិនិវត្តន៍ នៅថ្ងៃទី៩ វិច្ឆិកា ឆ្នាំ ២០១៩ របស់លោក សម រង្សី ជាកិរិយាវិរភាពមួយគួរអោយ កោតសរសើរ។ ថ្ងៃនោះ ជាថ្ងៃព្យុហយាត្រា ព្រោះគាត់ថ្លែងថា មានខ្មែរ២លាននាក់ រស់នៅប្រទេសថៃ ម៉ាឡេស៊ី និង កូរ៉ែខាងត្បូង នឹងចូលរួមជាមួយគាត់។ ការពោលអះអាងនេះ វាចោទជាបញ្ហា នៃការរៀបចំទ្រង់ទ្រាយធំ ក្នុងផ្នែកបច្ចេកទេស និងសម្ភារៈនៃការដឹកនាំ ដើម្បីដឹកជញ្ជូនមនុស្សចំនួន២លាននាក់ ចូលស្រុកខ្មែរក្នុងរយៈពេលតែមួយគត់។ សួរថា តើលោក សម រង្សី គាត់និយាយដោយហ្មត់ចត់ក្នុងឋានៈគាត់ជាប្រមុខ មានការទទួលខុសត្រូវ ? ឬ គាត់និយាយ ជាអារម្មណ៍ក្បាច់គុននៅក្នុងសុភោហារ របស់គាត់តែប៉ុណ្ណោះ ? តែទោះបីយ៉ាងណា ក៏មិនត្រូវវាយតម្លៃស្រាលលើការអះអាងនោះដែរ ព្រោះថា ចុះបើមានខ្មែររាប់លាននាក់នៅក្នុងស្រុក រង់ចាំស្វាគមន៍គាត់, ព្រឹត្តិការណ៍នោះ វានឹងអាចជាប្រទូលមួយ សំរាប់របបភ្នំពេញជាពុំខាន ព្រោះថា ដើម្បីចាប់គាត់ដាក់ខ្នោះ ប៉ូលីសរបស់ ហ៊ុន សែន ត្រូវចាំបាច់រើកហ្វូងជនខ្មែររាប់លាននាក់ ទើបធ្វើបាន។ ព្រឹត្តិការណ៍បែបនេះ៦ង បើសិនជាមានកើតឡើង គឺពិតជា រង្សី គាត់នឹងក្លាយជាវិជយិន នៅចំពោះមុខរបបផ្តាច់ការ។ តែថា នៅពេលដែលពួកឈ្លបរបស់ ហ៊ុន សែន ចាប់ កឹម សុខា ដាក់ខ្នោះ វាគ្មានប្រជាប្រតិកម្មអ្វីកើតឡើងសោះ។ សួរថាតើ រង្សី និង សុខា ជាមនុស្សតែមួយ ?

ឧប សៅ សង្ហា **គំនិត** **២៣ សីហា ២០១៩**